ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# កិច្ចព្រមព្រៀង

នាថ្ងៃទី០១ ខែ មិថុនា ឆ្នាំ ២០២០ វេលាម៉ោង ២ រសៀល នៅក្រុមហ៊ុន វ៉ាសាន់ អេចខេ ហ្វេកធើរី (ខេមបូឌា) ខូអិលធីឌី បានបើកកិច្ចប្រជុំពិភាក្សាការងារដោយមានវត្តមានចូលរួមពី ប្រធានផលិតកម្ម តំណាងកម្មករ សហជីពប្រចាំមូលដ្ឋាន ប្រធានក្រុមគ្រប់ផ្នែក ស្តីពីការស្នើសុំព្យួរកិច្ចសន្យាការងារ។

**កម្មវត្ថុ ៖** សំណើរសុំព្យួរកិច្ចសន្យាការងាររបស់កម្មករនិយោជិត។

**យោង ៖** មាត្រា ៧១ និង មាត្រា ៧២ នៃច្បាប់ស្តីពីការងាររបស់ព្រះរាជាណាចក្រកម្ពុជា។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និង យោងខាងលើនេះ ដោយសារតែក្រុមហ៊ុនយើងខ្ញុំត្រូវបានលុបការបញ្ជាទិញ និងគ្មានការបញ្ជាទិញពីអតិថិជន ដែលទាក់ទងនឹងផលប៉ះពាល់ពីជំងឺរាលដាលផ្លូវដង្ហើមធ្ងន់ធ្ងរ (កូវីដ ១៩ COVID-19)។ ដូច្នេះក្រុមហ៊ុនយើងខ្ញុំស្នើសុំព្យួរកិច្ចសន្យាការងារកម្មករនិយោជិតចំនួន ១៤ នាក់ រយៈពេល ២៧ថ្ងៃ ដោយគិតចាប់ពីថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ ២០២០ រហូតដល់ថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០២០។

ហើយក្នុងរយៈពេលព្យួរការងារក្នុងមួយខែនេះក្រុមហ៊ុននឹងផ្តល់ប្រាក់ឧបត្ថម្ភចំនួន ៣០ដុល្លាអាមេរិកសម្រាប់កម្មករនិយោជិតម្នាក់ៗក្នុងមួយខែ ក្នុងនោះមានដូចខាងក្រោម៖

-សម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេល ៧ ថ្ងៃ ដល់ ១០ ថ្ងៃ ទទួលបាន ១០ដុល្លាអាមេរិក

-សម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេល ១១ ថ្ងៃ ដល់ ២០ ថ្ងៃ ទទួលបាន ២០ដុល្លាអាមេរិក

-សម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេល ២១ ថ្ងៃ ដល់ ១ ខែ ទទួលបាន ៣០ដុល្លាអាមេរិក

ដោយយោងមាត្រាខាងលើ ភាគីទាំងអស់គ្នាបានឯកភាពគ្នាព្យួរកិច្ចសន្យាការងារចាប់ពីថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ ២០២០ រហូតដល់ថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០២០។

កិច្ចប្រជុំនេះបានចប់សព្វគ្រប់ នៅថ្ងៃ ខែ ឆ្នាំ ដដែលក្រោមបរិយាកាសដ៏សែនរីករាយ។ ភាគីទាំងសងខាងបានឯកភាពគ្នាអនុវត្តន៍លើកិច្ចព្រមព្រៀង និង សូមផ្តិតមេដៃចុះហត្ថលេខាក្នុងតារាងចុះវត្តមាន ទុកជាភស្តុតាងដូចខាងក្រោមនេះ ៖

ធ្វើនៅកំពង់ស្ពឺ,ថ្ងៃទី០១ ខែខែ មិថុនា ឆ្នាំ ២០២០

ភាគីតំណាងកម្មករ-សហជីពមូលដ្ឋាន

0F-005

0F-146

I3-2-045

ភាគីភាគីក្រុមហ៊ុន

ព្រះរាជាណាចក្រកម្ពុជា

WAH SUN HK FACTORY (CAMBODIA) CO.,LTD.

KINGDOM OF CAMBODIA